# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-May-2013, 13:11
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សំណើសុំដាក់បញ្ចូលសារទូរលេខតាមផ្លូវទូតអាមេរិកនៅក្នុងការពិភាក្សាដេញដោល អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង

---

ដាក់ដោយ៖

**មេធាវីការពារក្ដី លោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ូរ ឧត្ដារា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mathilde CHIFFERT

កញ្ញា Vera MANUELLO

កញ្ញា អ៊ូច ស្រីផាត់

លោកស្រី សុគន្ធ មោនីកា

កញ្ញា Blandine ZELLER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣ មេធាវីការពារក្តី លោក ខៀវ សំផន បានរកឃើញពីអត្ថិភាព និងការបញ្ចេញផ្សាយជាសាធារណៈនូវសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក ដោយមូលដ្ឋានទិន្នន័យរបស់គេហទំព័រ Wikileaks។ ការបញ្ចេញសារទូរលេខទាំងអស់នេះត្រូវបានចុះផ្សាយក្នុងអត្ថបទសារព័ត៌មានចេញផ្សាយថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣[1]។

២. នៅថ្ងៃនេះ ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង មេធាវីការពារក្តីស្នើសុំដាក់សារទូរលេខការទូតអាមេរិកទាំង ១៤ ដែលមាននៅក្នុងឧបសម្ព័ន្ធ ១ នៃសំណើសុំនេះ បញ្ចូលទៅក្នុងការពិភាក្សាដេញដោល និងត្រូវបានទទួលយកធ្វើជាភស្តុតាង។

## I. ច្បាប់ជាធរមាន

៣. វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងចែងថា៖ "*ក្នុងអំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬ តាមការស្នើសុំរបស់ភាគី (...) [អង្គជំនុំជម្រះអាច]ទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត*"។

៤. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនកាលពីខែ មេសា ឆ្នាំ ២០១២ ទាក់ទិននឹងឯកសារថ្មីៗ អង្គជំនុំជម្រះបានសម្រេចថា៖ "*ទាក់ទិននឹងឯកសារទាំងអស់ដែលមិនបានបញ្ចូលក្នុងបញ្ជីរបស់ភាគីដែលបានដាក់ទៅតាមដីកាបង្គាប់ពីមុនៗរបស់អង្គជំនុំជម្រះ ភាគីមិនត្រូវបានរារាំងក្នុងការដាក់ពាក្យសុំបន្ថែមនាពេលអនាគតដើម្បីសុំការទទួលយកឯកសាររបស់ខ្លួនអនុលោមតាមវិធាន ៨៧(៤) នោះទេ ប្រសិនបើភាគីយល់ថាឯកសារថ្មីដែលខ្លួនស្នើសុំដាក់នោះ ផ្តល់ប្រយោជន៍ដល់យុត្តិធម៌*"[2]។

---

[1] អត្ថបទកាសែតភ្នំពេញប៉ុស្តិ៍ មានចំណងជើងថា "*The Kissinger Cable*" ចេញផ្សាយថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣។ អត្ថបទកាសែត ខ្មែរ ឃេមបូឌា ដេលី មានចំណងជើងថា "*Kissinger Cables' Reveal Cambodia's Darkest Hours*" ចេញផ្សាយថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣។

[2] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E190 កថាខណ្ឌ ២១។

## II. សំណើសុំអាចទទួលយកបាន

៥. អនុលោមតាមវិធាន ៨៧(៤) សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិកទាំង១៤ ដែលមានចែងក្នុងឧបសម្ព័ន្ធ១ មិនអាចត្រូវរកបាននៅមុនពេលចាប់ផ្តើមសវនាការឡើយ។

៦. នៅថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៣ សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិកទាំងនោះត្រូវបានដាក់នៅលើប្រព័ន្ធអ៊ីនធឺណែត តាមរយៈមូលដ្ឋានទិន្នន័យរបស់គេហទំព័រ Wikileaks។ នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣ មេធាវីការពារក្តីបានដឹងអំពីការបញ្ចេញនូវសារទូរលេខទាំងអស់នោះក្រោយពីមានការចេញផ្សាយនូវអត្ថបទសារព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងប្រធានបទនេះ។ ភ្លាមៗបន្ទាប់ពីមានការចេញផ្សាយសារទូរលេខទាំងអស់នោះជាសាធារណៈ មេធាវីការពារក្តីបានធ្វើការពិនិត្យយ៉ាងយកចិត្តទុកដាក់នូវមូលដ្ឋានទិន្នន័យដែលមានឈ្មោះថា *"Kissinger Cables"* ដែលមានផ្ទុកទៅដោយសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិកជាងមួយលានឯកសារ។ មេធាវីការពារក្តីបានជ្រើសរើសសារទូរលេខចំនួន១៤ ដែលខ្លួនគិតថាមានសារៈប្រយោជន៍ដល់ការស្វែងរកការពិត។ នៅថ្ងៃនេះ មេធាវីការពារក្តីដាក់សំណើសុំឱ្យទទួលយកសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិកទាំង១៤ នេះ ធ្វើជាឯកសារភស្តុតាង។

៧. ម្យ៉ាងវិញទៀត មេធាវីការពារក្តីមានបំណងគូសបញ្ជាក់ថា សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋ-អាមេរិកទាំង១៤ នេះ ពិតជាមានសារៈប្រយោជន៍ក្នុងការស្វែងរកការពិត។ ឯកសារទាំងនេះពិតជាមានសារៈសំខាន់ សម្រាប់ការវាយតម្លៃមួយប្រកបដោយភាពត្រឹមត្រូវល្អឥតខ្ចោះពីអង្គហេតុដែលបានកើតឡើងនៅមុន និងក្រោយឆ្នាំ១៩៧៥ ក៏ដូចជាសម្រាប់អង្គហេតុដែលបានកើតឡើងក្នុងទសវត្សរ៍ឆ្នាំ២000 ហើយដែលក្នុងចំណោមសារទូរលេខទាំង១៤នោះ មានសារទូរលេខមួយចំនួនត្រូវបានសហព្រះរាជអាជ្ញាយល់ឃើញថាជាភស្តុតាងសំខាន់របស់ខ្លួន។

៨. សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិកទាំង១៤ នោះ បង្ហាញពីពាក្យសំដីដែលត្រូវបានចង-ក្រងឡើងដោយស្ថានទូតអាមេរិកនៅភ្នំពេញ[3] វ៉ាបា[4] ប៉ៃលក្រាដ[5] ប៉េកាំង[6] វៀងចន្ទន៍[7] និង មូស្គូ[8] ឬ

[3] សូមមើល សារទូរលេខតាមផ្លូវទូតលេខ១ សារទូរលេខតាមផ្លូវទូតលេខ៥ សារទូរលេខតាមផ្លូវទូតលេខ៨ សារទូរលេខតាមផ្លូវទូតលេខ៩ សារទូរលេខតាមផ្លូវទូតលេខ១០ សារទូរលេខតាមផ្លូវទូតលេខ១៣ និងសារទូរលេខតាមផ្លូវទូតលេខ១៤។

ក៏ជាសំដីនិយាយដោយ លោក Henry Kissinger[9] និងរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកនាសម័យនោះ[10]។ ផ្ទុយពីសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិកដែលសហព្រះរាជអាជ្ញាបានស្នើសុំដាក់បញ្ចូលទៅក្នុងសំណុំរឿង[11] ហើយដែលការស្នើសុំនេះត្រូវបានជំទាស់ដោយមេធាវីការពារក្ដី[12] សារទូរលេខទាំង១៤ នោះ បានបង្ហាញពីប្រភពនៃសំដីដែលត្រូវបានគេរាយការណ៍ ដែលភាគច្រើនសុទ្ធសឹងជាកិច្ចសម្ភាស និងជាសុន្ទរកថាថ្លែងជាសាធារណៈ។ ដូច្នេះ សារទូរលេខទាំង១៤នេះ ពិតជាសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង ស្របតាមខ្លឹមសារនៃវិធាន ៨៧(៣)(គ)។ម្យ៉ាងវិញទៀត ព័ត៌មានដែលមាននៅក្នុងសារទូរលេខមួយចំនួនក្នុងចំណោមសារទូរលេខទាំងអស់នោះ ត្រូវបានគាំទ្រដោយឯកសារមួយចំនួនដែលត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ខាងក្រោមនេះ មេធាវីការពារក្ដីសូមធ្វើការពន្យល់ពីភាពពាក់ព័ន្ធ និងភាពសមស្របរបស់សារទូរលេខតាមផ្លូវទូតទាំង១៤ សម្រាប់បញ្ជាក់អង្គហេតុដែលជាគោល-ដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង។

៩. មេធាវីការពារក្ដីសូមអះអាងថា សំណើសុំរបស់ខ្លួនពិតជាត្រឹមត្រូវទៅតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ដោយអង្គជំនុំជម្រះក្នុងការទទួលយកឯកសារថ្មីៗអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

## III. សំណើសុំមានសំអាងហេតុត្រឹមត្រូវស្របទៅតាមលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន ៨៧(៣)

---

[4] សារទូរលេខតាមផ្លូវទូតលេខ២។

[5] សារទូរលេខតាមផ្លូវទូតលេខ៣។

[6] សារទូរលេខតាមផ្លូវទូតលេខ៤។

[7] សារទូរលេខតាមផ្លូវទូតលេខ៧។

[8] សារទូរលេខតាមផ្លូវទូតលេខ១១។

[9] សារទូរលេខតាមផ្លូវទូតលេខ៦។

[10] សារទូរលេខតាមផ្លូវទូតលេខ១២។

[11] តាមរយៈសំណើនេះ សហព្រះរាជអាជ្ញាបានស្នើឲ្យទទួលយកសារទូរលេខតាមផ្លូវទូតដែលទើបត្រូវរកបានថ្មីៗធ្វើជាភ័ស្តុតាងសម្រាប់ការជំនុំជម្រះ ឯកសារ E282 ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣។

[12] ចម្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាដែលស្នើឲ្យមានការដាក់បញ្ចូលសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិកទៅក្នុងសំណុំរឿង ឯកសារ E282/1 ចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៣។

១០. មេធាវីការពារក្តីសូមគូសបញ្ជាក់ថា សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិកទាំង១៤ ដែលជាកម្មវត្ថុនៃសំណើសុំនេះ ពិតជាមានសារៈប្រយោជន៍ក្នុងការស្វែងរកការពិត និងបំពេញបាននូវរាល់ល័ក្ខខ័ណ្ឌតម្រូវដែលមានចែងនៅក្នុងកថាខណ្ឌ៣ នៃវិធាន ៨៧[13]។

## ក. ពាក់ព័ន្ធនឹងកេរ្តិ៍ឈ្មោះ និងវត្តមានមិនអាចខ្វះបានរបស់ លោក ខៀវ សំផន នៅក្នុងចលនាខ្មែរក្រហម

១១. សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិកចំនួនបួនក្នុងចំណោមសារទូរលេខទាំង១៤ ពិតជាមានភាពពាក់ព័ន្ធ ស្របទៅតាមបញ្ញត្តិនៃវិធាន ៨៧(៣) ព្រោះសារទូរលេខទាំងបួននោះគឺជាភ័ស្តុតាងដែលបង្ហាញថា ដោយសារ លោក ខៀវ សំផន ជាមនុស្សមានកេរ្តិ៍ឈ្មោះល្អ និងមានឥទ្ធិពលខ្មែរក្រហមបានមើលឃើញពីសារៈប្រយោជន៍ពិសេសមួយក្នុងការដាក់រូបលោក ឲ្យធ្វើជាបុគ្គលសំខាន់របស់ចលនារណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នៅលើឆាកជាតិ និងអន្តរជាតិ។

១២. **សារទូរលេខតាមផ្លូវទូតលេខ៧** ជាភ័ស្តុតាងបង្ហាញថាកងកម្លាំងនៃអ្នកប្រឆាំងខ្មែរបានមើលឃើញពីសារៈប្រយោជន៍ក្នុងការឲ្យលោក ខៀវ សំផន ធ្វើជាអ្នកដឹកនាំនៅលើឆាកអន្តរជាតិជំនួសព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ។ សារទូរលេខនេះពន្យល់ថាការណ៍ដែលឲ្យលោក ខៀវ សំផន ធ្វើជាអ្នកដឹកនាំនៅលើឆាកអន្តរជាតិនេះគឺដើម្បីបង្កើតឲ្យមានឥទ្ធិពលដល់ការបោះឆ្នោតនៅអង្គការសហប្រជាជាតិដែលត្រូវរៀបចំឡើងនៅឆ្នាំ១៩៧៤ និងដើម្បីឲ្យចលនារណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាទទួលបានការទុកចិត្តនៅក្នុងកម្រិតអន្តរជាតិ[14]។ លើសពីនេះទៅទៀត សារទូរលេខនេះបានអះអាងថា បើធៀបទៅនឹងព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ដែលត្រូវបានគេចាត់ទុកថាជាមនុស្សមិនអាចទុកចិត្តបាន[15] លោក ខៀវ សំផន មានកេរ្តិ៍

[13] “(...) អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា ៖ ក-មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ-មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ឃ-ច្បាប់មិនអនុញ្ញាត ឬ ង-មានចេតនាពន្យាកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។”

[14] សារទូរលេខតាមផ្លូវទូតលេខ៧ កថាខណ្ឌ១) គ)។

[15] សារទូរលេខតាមផ្លូវទូតលេខ៧ កថាខណ្ឌ១) គ)។

ឈ្មោះជាមនុស្សស្អាតស្អំ និងជាបញ្ញាជន។

១៣. **សារទូរលេខតាមផ្លូវទូតលេខ១** បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថាចលនារណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានទទួលផលចំណេញយ៉ាងសម្បើមក្នុងការដាក់ឲ្យ លោក ខៀវ សំផន ធ្វើជាបុគ្គលឈានមុខគេនៅក្នុងឆាកជាតិ និងជាពិសេសក្នុងចំណោមបញ្ញាជន និងនិស្សិតនៅទីក្រុងភ្នំពេញ ហើយដែលពួកគេមួយចំនួនធំបានស្ងើចសរសើរ លោក ខៀវ សំផន ថាជាមនុស្សស្អាតស្អំ និងជាអ្នកចេះដឹង[16]។

១៤. **សារទូរលេខតាមផ្លូវទូតលេខ៥** បង្ហាញថា តាមរយៈកេរ្តិ៍ឈ្មោះរបស់លោកជាតំណាងរាស្ត្រ និងជារដ្ឋមន្ត្រីស្អាតស្អំនៃរបបមុន និងដោយលោកបានប្រឆាំងទៅនឹងភាពឃោរឃៅរបស់របបព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ លោក ខៀវ សំផន គឺជាមនុស្សដែលត្រូវបានគេស្គាល់ច្រើនជាងគេនៅក្នុងចលនាខ្មែរក្រហម។ សារទូរលេខនេះ ថែមទាំងបានទទួលស្គាល់ផងដែរថាលោក ខៀវ សំផន ត្រូវបានជ្រើសរើសឲ្យធ្វើជាអ្នកនាំពាក្យដ៏សំខាន់មួយរូបសម្រាប់ចលនាខ្មែរក្រហមនៅបរទេស[17]។ ម្យ៉ាងវិញទៀត សារទូរលេខបានបញ្ជាក់ថាវត្តមានរបស់លោក ខៀវ សំផន នៅលើឆាកអន្តរជាតិ ជំនួសព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ បង្ហាញថាព្រះអង្គមិនមានប្រយោជន៍ក្នុងការធ្វើជាអ្នកនាំពាក្យការទូតសម្រាប់ចលនាខ្មែរក្រហមឡើយ[18]។

១៥. **សារទូរលេខតាមផ្លូវទូតលេខ៦** ដែលត្រូវបានសរសេរដោយ លោក Henry Kissinger ខ្លួនឯងផ្ទាល់ បានអះអាងថាអ្នកបះបោរខ្មែរក្រហមមិនអាចបំភ្លេចបានឡើយនូវការធ្វើបាប និងការបង្ក្រាបរបស់ព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ[19] ប្រឆាំងនឹងពួកកសិករខ្មែរ។ សារទូរលេខនេះ ជាភ័ស្តុតាងបញ្ជាក់ថា ភាពស្អាតស្អំ និងសេចក្តីក្លាហានរបស់ លោក ខៀវ សំផន នៅក្នុងរបបពុករលួយរបស់ព្រះករុណាព្រះបរមរតនកោដ្ឋ បានធ្វើឲ្យលោកទទួលបានការកោតស្ញប់ស្ញែងយ៉ាងសម្បើមនៅក្នុងប្រទេស[20]។

[16] សារទូរលេខតាមផ្លូវទូតលេខ១ កថាខណ្ឌ៥។

[17] សារទូរលេខតាមផ្លូវទូតលេខ៥ កថាខណ្ឌ៥។

[18] សារទូរលេខតាមផ្លូវទូតលេខ៥ កថាខណ្ឌ៦។

[19] សារទូរលេខតាមផ្លូវទូតលេខ៦ កថាខណ្ឌ១។

[20] សារទូរលេខតាមផ្លូវទូតលេខ៦ កថាខណ្ឌ២។

១៦. ព័ត៌មានដែលមានភាពពាក់ព័ន្ធ និងមានសារៈប្រយោជន៍ដល់ការស្វែងរកការពិតទាំងនេះត្រូវបានគាំទ្រដោយសក្ខីកម្មដែលត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយដែលសក្ខីកម្មទាំងអស់នោះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងផងដែរ[21]។

## ខ. អំពីអំណាចរបស់លោក ខៀវ សំផន មុន និងក្រោយឆ្នាំ ១៩៧៥

១៧. សារទូរលេខចំនួនបួន ក្នុងចំណោមសារទូរលេខដែលជាកម្មវត្ថុនៃសំណើសុំនេះ បានបញ្ជាក់អំពីតួនាទីរបស់លោក ខៀវ សំផន និងអំណាចដែលគាត់មានមុនឆ្នាំ ១៩៧៥ នៅក្នុងជួរចលនា FUNK និង GRUNK និងអំណាចរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រោយឆ្នាំ ១៩៧៥។ ពិសេសជាងនេះទៅទៀត សារទូរលេខទាំងនោះបានបង្ហាញភ័ស្តុតាងដែលលាតត្រដាងអំពីអំណាចពិតប្រាកដ និងអំណាចជាក់ស្តែង ដែលលោក ខៀវ សំផន បានអនុវត្តនៅក្នុងអំឡុងនៃសម័យកាលបន្តបន្ទាប់គ្នានោះ ហើយដែលអំណាចទាំងពីរនេះត្រូវតែបែងចែកឲ្យដាច់ពីគ្នា។ ផ្អែកលើឯកសារភ័ស្តុតាងដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរហូតមកទល់នឹងពេលនេះ សារទូរលេខផ្លូវទូតទាំងនេះបានបញ្ជាក់កាន់តែច្បាស់អំពីតួនាទីបែបពិធីការ និងជានិមិត្តរូបសុទ្ធសាធរបស់លោក ខៀវ សំផន នៅក្នុងជួរនៃចលនាខ្មែរក្រហម នាមុន និងក្រោយឆ្នាំ ១៩៧៥។

១៨. ជាមួយគ្នានេះ ពាក់ព័ន្ធនឹងសម័យកាលមុនឆ្នាំ ១៩៧៥ **សារទូរលេខតាមផ្លូវទូតលេខ៥** បានជម្រះនូវភាពស្រពេចស្រពិលពាក់ព័ន្ធនឹងតួនាទីរបស់លោក ខៀវ សំផន (អគ្គមេបញ្ជាការនៃចលនាបះបោរខ្មែរ និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ) ព្រមទាំងបានបញ្ជាក់អំពីអវត្តមានជាបន្តបន្ទាប់គ្នាពីក្នុងប្រទេសរបស់ លោក ខៀវ សំផន ក្នុងអំឡុងពេលនៃការវាយប្រយុទ្ធតាមផ្លូវយោធាដ៏ក្តៅគគុកនានា

---

[21] ឧទាហរណ៍ សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី Laurence PICQ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ E3/353 ទំព័រ៣។ សៀវភៅនិពន្ធដោយលោក Philip SHORT មានចំណងជើងថា *"Pol Pot, Anatomie d'un cauchemard"* ឯកសារ E3/9 ទំព័រ៣៤៥។ ប្រតិចារឹកសវនាការថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ E1/189.1 ទំព័រ៤៨-៤៩ និងទំព័រ ៥១-៥២ (ភាសាបារាំង)។ ប្រតិចារឹកសវនាការថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/178.1 ទំព័រ១០-១១ (ភាសាបារាំង)។ ប្រតិចារឹកសវនាការថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/179.1 ទំព័រ៨១ និងទំព័រ៨៣ (ភាសាបារាំង)។ ប្រតិចារឹកសវនាការថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/55.1 ទំព័រ៥៣-៥៤ (ភាសាបារាំង)។

ដោយហេតុលោកជាប់ធ្វើដំណើរទៅបរទេស។ តាមរយៈសារទូរលេខនោះ សាឡុត ស ជាក់ស្តែងគឺជាមេបញ្ជាការកំពូលនៃកងទ័ពខ្មែរក្រហម[22]។ ស្ថានទូតសហរដ្ឋអាមេរិកបានវាយតម្លៃថា បើទោះបីជាលោក ខៀវ សំផន មានតួនាទីក្នុងជួរយោធាក៏ដោយ ក៏លោកពុំមែនជាមេដឹកនាំដែលមានអំណាចលើផ្នែកនយោបាយ និងយោធាដែរ ដោយហេតុថា ប្រសិនណាជាលោកមានអំណាចបញ្ជាទ័ពមែន នោះប្រាកដជាលោក ខៀវ សំផន មានវត្តមាននៅក្នុងសមរភូមិ នាសម័យកាលសង្គ្រាមដ៏សន្ធោសន្ធៅក្នុងប្រទេសកម្ពុជាហើយ[23]។ ក្រៅពីនេះ **សារទូរលេខតាមផ្លូវទូតលេខ៦** បានលើកនូវភ័ស្តុតាងដែលបង្ហាញអំពីភាពស្រពេចស្រពិលជាក់ស្តែង ពាក់ព័ន្ធនឹងវិសាលភាពនៃអំណាចរបស់លោក ខៀវ សំផន មុនឆ្នាំ ១៩៧៥។ លោក Henry Kissenger បានពន្យល់ថា ទោះបីជាលោក ខៀវ សំផន មានតួនាទីជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គមេបញ្ជាការកងទ័ពខ្មែរក្រហមក៏ដោយ ក៏លោក ខៀវ សំផន ប្រហែលជាពុំដែលបានចូលប្រឡូកក្នុងសកម្មភាពដែលពាក់ព័ន្ធនឹងយុទ្ធវិធីយោធាឡើយ។ ជាក់ស្តែង លោក Kissenger បានកត់សម្គាល់លើចំណុចមួយដែលមានលក្ខណៈសមហេតុសមផលបំផុត គឺថាមន្ត្រីយោធាក្នុងកម្រិតកំពូលម្នាក់មិនអាចអវត្តមានពីសមរភូមិប្រយុទ្ធដ៏សន្ធោសន្ធៅមួយ ដូចតួយ៉ាងសង្គ្រាមនារដូវប្រាំងក្នុងប្រទេសកម្ពុជានោះទេ[24]។

១៩. ព័ត៌មានដែលផ្តល់តាមរយៈសារទូរលេខតាមផ្លូវទូតទាំងនេះ មានលក្ខណៈកាត់តែពិតប្រាកដថែមទៀត ជាពិសេស បើផ្អែកលើសក្ខីកម្មនានាដែលបានផ្តល់ដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងក្របខណ្ឌនៃសំណុំរឿងទីមួយនោះ[25]។

២០. ពាក់ព័ន្ធនឹងសម័យកាលក្រោយឆ្នាំ ១៩៧៥ **សារទូរលេខតាមផ្លូវទូតលេខ ១១** បានបង្ហាញនូវភ័ស្តុតាងដែលបញ្ជាក់ថា អតីតសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតពុំបានចាត់ទុកលោក ខៀវ សំផន ថាជាសមាជិកការិយាល័យនយោបាយនៃរបបថ្មីឡើយ។ សារទូរលេខនោះបានពន្យល់

---

[22] សារទូរលេខតាមផ្លូវទូតលេខ៥ កថាខណ្ឌ ៥។

[23] សារទូរលេខតាមផ្លូវទូតលេខ៥ កថាខណ្ឌ ៦ (គ)។

[24] សារទូរលេខតាមផ្លូវទូតលេខ៦ កថាខណ្ឌ ៤។

[25] ឧទាហរណ៍ សូមមើល ប្រតិចារឹកសវនាការ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/55.1 ទំព័រ ៤៩, ៥១, ៥៣ និង ៥៤ (ភាសាបារាំង)។ ប្រតិចារឹកសវនាការ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E1/68.1 ទំព័រ ៥២ (ភាសាបារាំង)។

ថា លោក ខៀវ សំផន ស្ថិតនៅលំដាប់ទី ១០ ឬទី ១៥ នៃឋានានុក្រមថ្នាក់ដឹកនាំខ្មែរក្រហម[26]។ ជាមួយគ្នានេះ **សារទូរលេខតាមផ្លូវទូតលេខ ១២** បានបង្ហាញយ៉ាងច្បាស់ថា សុន សេន បានមកជំនួស ខៀវ សំផន ក្នុងមុខតំណែងយោធារបស់គាត់។ សារទូរលេខនោះក៏បានលើកឡើងផងដែរអំពីពាក្យចចាមអារ៉ាមដែលថាលោក ខៀវ សំផន ត្រូវបាន គេដកចេញពីតំណែងនោះ[27]។

២១. អង្គហេតុដែលទទួលបានពីសារទូរលេខអស់ទាំងនេះកាន់តែមានទម្ងន់ថែមទៀត តាមរយៈឯកសារភ័ស្តុតាងដែលបានដាក់ចូលទៅក្នុងសំណុំរឿងតាំងពីដំណាក់កាលស៊ើបសួរ ពោលគឺសារទូរលេខផ្លូវទូតនានារបស់ស្ថានទូតបារាំង[28] និងសារទូរលេខផ្លូវទូតមួយច្បាប់របស់សហរដ្ឋអាមេរិក[29]។

## គ. <u>អំពីការសងសឹកជាលក្ខណៈបុគ្គលរបស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ នៅលើពួកមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ</u>

២២. សារទូរលេខផ្លូវទូតចំនួនប្រាំពីរ ក្នុងចំណោមសារទូរលេខផ្លូវទូតទាំងឡាយដែលត្រូវបានស្នើសុំដាក់បញ្ចូលក្នុងសំណុំរឿង បានផ្តល់ភ័ស្តុតាងដែលបង្ហាញថា សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះអង្គមានបំណងធ្វើការសងសឹកជាលក្ខណៈបុគ្គលផ្ទាល់ ទៅលើពួកមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ។ ជាមួយគ្នានោះ សម្តេចព្រះបរមរតនកោដ្ឋ ព្រះអង្គបានធ្វើការបដិសេធយ៉ាងដាច់អហង្កា ក្នុងការចរចាជាមួយមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ រួមទាំងការស្វែងរកកិច្ចព្រមព្រៀង និងបង្កើតរដ្ឋាភិបាលចម្រុះជាមួយគ្នា។ ព្រះអង្គទ្រង់ថែមទាំងបានធ្វើការវាយប្រហារតាមរយៈពាក្យសម្តីធ្ងន់ៗ ទៅលើពួកមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរនោះទៀតផង។

២៣. សារទូរលេខតាមផ្លូវទូតទាំងនេះបានដកស្រង់ព្រះបន្ទូលរបស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម

---

[26] សារទូរលេខតាមផ្លូវទូតលេខ១១ កថាខណ្ឌ ៧។

[27] សារទូរលេខតាមផ្លូវទូតលេខ១២ កថាខណ្ឌ ៣។

[28] ឧទាហរណ៍ សូមអានកំណត់ហេតុផ្ទៃក្នុង ដែលមានចំណងជើងថា "ដីកាអមរួមលេខ ១១៦" ឯកសារ E3/2657 ទំព័រ ៣។ កំណត់ហេតុចំពោះអង្គការ OTAN ដែលមានចំណងជើងថា "ដំណើរវិវត្តន៍ថ្មីៗក្នុងវិស័យនយោបាយនៅប្រទេសកម្ពុជា" ឯកសារ E3/493 ទំព័រ ៤, កំណត់ហេតុផ្ទៃក្នុង ដែលមានចំណងជើងថា "ដីកាអមរួមលេខ ៣៣៥" ឯកសារ E3/484 ទំព័រ ៧។

[29] កំណត់ហេតុផ្ទៃក្នុង ដែលមានចំណងជើងថា៖ "សេចក្តីប្រកាសព័ត៌មានអំពីឧបនាយករដ្ឋមន្ត្រីថ្មីពីររូប នៅកម្ពុជា" ឯកសារ E3/3348 ទំព័រ ២។

សីហនុ ដែលបានបដិសេធមិនទទួលយកការចរចាណាមួយជាមួយលោក លន់ នល់ ព្រមទាំង "រដ្ឋាភិបាល ខ្ញុំកញ្ជះដាច់ថ្លៃ និងក្បត់ជាតិរបស់លោក"[30] ហើយរណសិរ្សរួបរួមជាតិកម្ពុជានឹងមិនធ្វើការចរចាណាមួយជាមួយនឹង "*បនក្បត់ជាតិ និងចៅហ្វាយនាយរបស់ខ្លួនគឺចក្រពត្តិអាមេរិក*"[31]។ សារទូរលេខមួយចំនួនបានលើកឡើងអំពីការបដិសេធរបស់ព្រះអង្គ ក្នុងការបង្កើតរដ្ឋាភិបាលចម្រុះជាមួយរបបសាធារណរដ្ឋខ្មែរ[32]។ ជាពិសេស **សារទូរលេខតាមផ្លូវទូតលេខ ៨** បានបង្ហាញអំពីភាពប្រឆាំងគ្នាយ៉ាងជ្រាលជ្រៅរវាងជំហាររបស់មេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ និងជំហាររបស់សម្តេចព្រះបរមរតនកោដ្ឋ ពាក់ព័ន្ធទៅនឹងដំណើរការចរចាស្វែងរកសន្តិភាព។ សារទូរលេខទាំងនេះបានបញ្ជាក់អំពីជំហាររបស់សម្តេចព្រះបរមរតនកោដ្ឋ ដែលបានធ្វើការច្រានចោលនូវរាល់ការធ្វើសំណើសុំស្វែងរកសន្តិភាព និងការចរចាជាមួយមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ។ ព្រះរាជសន្ទរកថារបស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ដែលបានដកស្រង់ដោយស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅភ្នំពេញ ត្រូវបានគេសង្កេតឃើញថាមានលក្ខណៈគ្រោតគ្រាត ជេរប្រទេចផ្តាសារ និងធ្វើការចោទប្រកាន់មកលើជនទាំងឡាយដែលព្រះអង្គចាត់ទុកថាជាជនក្បត់[33]។

២៤. កាន់តែធ្ងន់ធ្ងរជាងនេះទៅទៀត សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ បានសន្យាថា ព្រះអង្គនឹងមិនទទួលយកនូវកិច្ចព្រមព្រៀងណាមួយជាមួយសាធារណរដ្ឋខ្មែរឡើយ ហើយព្រះអង្គបានគំរាមបន្តធ្វើសង្គ្រាម ២០ ឆ្នាំ ទៅមុខទៀត ប្រសិនណាជាចាំបាច់ ដើម្បីដណ្តើមឲ្យបាននូវឯករាជ្យពេញបរិបូរណ៍[34]។

២៥. សារទូរលេខផ្លូវទូតទាំងនេះបានដកស្រង់ផងដែរ នូវព្រះរាជបន្ទូលដែលមានលក្ខណៈគ្រោតគ្រាតខ្លាំងរបស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ទៅលើមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ និងអ្នកដែលគាំទ្ររបបនេះ។ សារទូរលេខនោះបានលើកឡើងថា សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ បានចាត់ទុកមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរថាជា "ជនក្បត់"[35] ឬ "ជាជនក្បត់

[30] សារទូរលេខតាមផ្លូវទូតលេខ៣ កថាខណ្ឌ ៥។ សារទូរលេខតាមផ្លូវទូតលេខ៩ កថាខណ្ឌ ១-២។

[31] សារទូរលេខតាមផ្លូវទូតលេខ៣ កថាខណ្ឌ ១។

[32] សារទូរលេខតាមផ្លូវទូតលេខ៨ កថាខណ្ឌ ៣។

[33] សារទូរលេខតាមផ្លូវទូតលេខ៨ កថាខណ្ឌ ១-៣។

[34] សារទូរលេខតាមផ្លូវទូតលេខ៨ កថាខណ្ឌ ៣។

[35] សារទូរលេខតាមផ្លូវទូតលេខ៨ កថាខណ្ឌ ១-៣។ សារទូរលេខតាមផ្លូវទូតលេខ២ កថាខណ្ឌ ១។

មហាឧក្រិដ្ឋ"[36]។ នៅក្នុង**សារទូរលេខតាមផ្លូវទូតលេខ ១០** សម្ដេចព្រះបរមរតនកោដ្ឋ នរោត្ដម សីហនុ ថែមទាំងបានរាយនាមមនុស្សទាំង ២១ នាក់ ដែលព្រះអង្គបានចាត់ទុកថាជា "*ជនមហាក្បត់*" ដែលបានចូលដៃចូលជើងជាមួយរបបសាធារណរដ្ឋខ្មែរ។ សារទូរលេខនោះបានបង្ហាញឲ្យយើងឃើញថា សម្ដេចព្រះបរមរតនកោដ្ឋ នរោត្ដម សីហនុ បានធ្វើសេចក្ដីថ្លែងការណ៍ថា បុគ្គលទាំង ២១ រូបនោះនឹងត្រូវទទួលការកាត់ទោស ក្នុងនាមជាឧក្រិដ្ឋជនសង្គ្រាម បន្ថែមពីលើមេដឹកនាំទាំង ៧ រូប នៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានកាត់ទោសប្រហារជីវិតរួចហើយនោះ[37]។

## ឃ. <u>អំពីបញ្ហានៃការជ្រៀតជ្រែកចូលផ្នែកនយោបាយនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការបែកធ្លាយនៃព័ត៌មានដែលត្រូវបានចាត់ទុកថាមានលក្ខណៈសម្ងាត់បំផុត និងមជ្ឈមណ្ឌលឯកសារកម្ពុជា</u>

២៦. សារទូរលេខតាមផ្លូវទូតចំនួនពីរ ដែលត្រូវបានតាក់តែងដោយស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅភ្នំពេញ កាលពីឆ្នាំ ២០០០ បានបង្ហាញអំពីការជ្រៀតជ្រែកចូលខាងនយោបាយ អំពើពុករលួយប្រព្រឹត្តឡើងដោយភាគីជាតិ និងអំពើផលវិបាកនានាដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានជួបប្រទះ ក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន។

២៧. **សារទូរលេខតាមផ្លូវទូតលេខ១៣** បានលើកឡើងថា រឿងក្ដីនៅ អ.វ.ត.ក. អាចប្រព្រឹត្តទៅបានដោយគ្មានការជ្រៀតជ្រែកចូលផ្នែកនយោបាយ "*ធំដុំ*"ឡើយ[38]។ ដោយឡែក **សារទូរលេខតាមផ្លូវទូតលេខ១៤** បានបង្ហាញអំពីការជ្រើសរើសបុគ្គលិកសម្រាប់បម្រើការនៅការិយាល័យសហព្រះរាជអាជ្ញាចំនួនពីររូប ដើម្បីជាមធ្យោបាយក្នុងប្រើឥទ្ធិពលផ្នែកនយោបាយ។ ដោយឡែក នៅក្នុងសារទូរលេខនោះ បានលើកឡើងថា លោកស្រី ជា លាង ដែលជាសហព្រះរាជអាជ្ញាជាតិ ពុំបានបញ្ចេញមតិយោបល់អ្វីពាក់ព័ន្ធទៅនឹងការជ្រើសរើសបុគ្គលិក ដែលពួកគេទាំងនោះត្រូវបានតែងតាំងដោយរដ្ឋាភិបាលកម្ពុជា[39]។

---

[36] សារទូរលេខតាមផ្លូវទូតលេខ៩ កថាខណ្ឌ ២។

[37] សារទូរលេខតាមផ្លូវទូតលេខ១០ កថាខណ្ឌ ១, ២។

[38] សារទូរលេខតាមផ្លូវទូតលេខ១៣ កថាខណ្ឌ ១។

[39] សារទូរលេខតាមផ្លូវទូតលេខ១៤ កថាខណ្ឌ ៨។

២៨. ក្រៅពីនេះ **សារទូរលេខតាមផ្លូវទូតលេខ១៣** បានបង្ហាញភស្តុតាងដែលបញ្ជាក់ថា អង្គការសហប្រជាជាតិបានផ្ញើលិខិតមួយទៅកាន់ព្រះបរមរាជវាំងនៅភ្នំពេញ ដែលធានាអះអាងថា អ.វ.ត.ក. នឹងគោរពនូវគោលការណ៍ដែលប្រកាន់យកចំពោះព្រះបរមរតនកោដ្ឋ ហើយថា អ.វ.ត.ក. នឹងមិនបង្កើតនូវ "រឿងអាស្រូវ" ធ្វើឱ្យប៉ះពាល់ដល់អភ័យឯកសិទ្ធិដែលថ្វាយជូនសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ឡើយ[40]។

២៩. ដោយឡែក **សារទូរលេខតាមផ្លូវទូតលេខ១០** បានលើកឡើងអំពីការចោទប្រកាន់លើភាគីជាតិនៃ អ.វ.ត.ក. ថាបានប្រព្រឹត្តអំពើពុករលួយ បន្ទាប់ពីមានការធ្វើសវនកម្មពីសំណាក់កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ដែលហៅកាត់ថា UNDP[41]។ សារទូរលេខមិនបានលើកឡើងអំពីការចុះផ្សាយនូវរបាយការណ៍ណាមួយឡើយ។

៣០. **សារទូរលេខតាមផ្លូវទូតលេខ១៤** ក៏បានបង្ហាញនូវភស្តុតាងដែលបញ្ជាក់អំពីភាពរួញរារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ក្នុងការសហការជាមួយ អ.វ.ត.ក. ហើយជាពិសេសបានលើកឡើងអំពីផលលំបាកនានារបស់ អ.វ.ត.ក. ក្នុងការស្នើសុំឯកសារច្បាប់ដើមពី DC-Cam។ សារទូរលេខនោះបានបង្ហាញឱ្យយើងឃើញផងដែរថា អង្គការ DC-Cam បានស្នើសុំឱ្យរាល់អ្នកដែលចង់ពិនិត្យលើឯកសារច្បាប់ដើមនៅមជ្ឈមណ្ឌល ត្រូវបង់ប្រាក់ជូនដល់មជ្ឈមណ្ឌលចំនួន ៥ ដុល្លារសហរដ្ឋអាមេរិក ព្រមទាំងបញ្ជាក់អំពីឈ្មោះរបស់អ្នកស្នើសុំនោះផងដែរ[42]។ ចំណុចនេះបានបង្ហាញឱ្យឃើញអំពីភាពមិនស្មោះត្រង់ដែលអង្គការ DC-Cam មានមន្ទិលសង្ស័យចាប់តាំងពីពេលដែលបង្កើត អ.វ.ត.ក មកម្ល៉េះ រួមទាំងការមិនព្រមសហការរបស់ខ្លួនដល់ការស្វែងរកការពិត។ ព័ត៌មានទាំងនេះមានសារៈសំខាន់ដល់កិច្ចពិភាក្សានានាដែលបានធ្វើឡើង ក្នុងអំឡុងនៃការជំនុំជម្រះក្តីទាំងមូល ពាក់ព័ន្ធនឹងឯកសារភស្តុតាងជាសំណៅដើម។

៣១. ព័ត៌មានទាំងនេះកាន់តែត្រូវបានធ្វើឱ្យជឿជាក់ តាមរយៈឯកសារដកស្រង់ចេញពីសៀវភៅរបស់លោក Marcel LEMONDE ដែលមេធាវីការពារបានស្នើសុំដាក់បញ្ចូលជាឯកសារភស្តុតាងទៅ

---

[40] សារទូរលេខតាមផ្លូវទូតលេខ១៣ កថាខណ្ឌ ៨។

[41] សារទូរលេខតាមផ្លូវទូតលេខ១៣ កថាខណ្ឌ ៩។

[42] សារទូរលេខតាមផ្លូវទូតលេខ១៤ កថាខណ្ឌ ៧។

ក្នុងសំណុំរឿង[43]។

៣២. **សារទូរលេខតាមផ្លូវទូតលេខ១៣** បានបង្ហាញភ័ស្តុតាងដែលបញ្ជាក់ថា ព័ត៌មានទាំងឡាយដែលត្រូវបានចាត់ទុកថាមានលក្ខណៈសម្ងាត់បំផុត ត្រូវបានផ្សព្វផ្សាយដល់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅភ្នំពេញ។ ជាក់ស្តែង សារទូរលេខចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ បានបង្ហាញថា ស្ថានទូតសហរដ្ឋអាមេរិកបានដឹងអំពីចំនួន និងអត្តសញ្ញាណនៃបុគ្គលដែលនឹងត្រូវចាប់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្នដោយសហចៅក្រមស៊ើបអង្កេត ខណៈដែលព័ត៌មានទាំងនេះមានលក្ខណៈសម្ងាត់បំផុតនោះ[44]។ បន្ថែមពីលើនេះ សារទូរលេខនោះបានលើកឡើងថា ស្ថានទូតសហរដ្ឋអាមេរិកបានដឹងអំពីការស៊ើបអង្កេតធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។ ជាឧទាហរណ៍ ស្ថានទូតសហរដ្ឋអាមេរិកបានដឹងថា សក្ខីកម្មរបស់ ឌុច គឺជាធាតុផ្សំមួយដ៏សំខាន់ដែលសហព្រះរាជអាជ្ញាប្រើប្រាស់ជាសម្អាងដល់ការអនុវត្តទ្រឹស្តីបទ "*សហឧក្រិដ្ឋកម្មរួម*" របស់ខ្លួនទៅលើជនជាប់សង្ស័យដទៃទៀត[45]។ សារទូរលេខនេះបានបង្ហាញប្រាប់យើងថា ស្ថានទូតសហរដ្ឋអាមេរិកទទួលបានព័ត៌មានសម្ងាត់ទាំងនេះពីសំណាក់បុគ្គលិករបស់ អ.វ.ត.ក.[46]។

៣៣. ជាចុងក្រោយ **សារទូរលេខតាមផ្លូវទូតលេខ១៤** បានបង្ហាញភ័ស្តុតាងថា លោក Steve HEDER ត្រូវបានជ្រើសរើសឲ្យចូលបម្រើការងារនៅការិយាល័យសហព្រះរាជអាជ្ញា ក្នុងនាមជាជំនួយការរបស់សហព្រះរាជអាជ្ញាអន្តរជាតិ លោក Robert PETIT[47]។ ព័ត៌មាននេះមានលក្ខណៈសមហេតុសមផល បន្ទាប់ពីមានការកោះហៅលោក Steve HEDER ឲ្យចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

៣៤. មេធាវីការពារក្តីលោក ខៀវ សំផន យល់ឃើញថា សារទូរលេខផ្លូវទូតទាំងអស់ដែលបានលើកឡើង នៅក្នុងសំណើសុំនេះ មានលក្ខណៈសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃ

---

[43] សំណើសុំទី២ សុំដាក់បញ្ចូលអត្ថបទដកស្រង់ចេញពីសៀវភៅរបស់លោក Marcel LEMONDE ទៅក្នុងកិច្ចពិភាក្សាដេញដោល ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ E280/2។

[44] សារទូរលេខតាមផ្លូវទូតលេខ១៣ កថាខណ្ឌ ២ និង ៦។

[45] សារទូរលេខតាមផ្លូវទូតលេខ១៣ កថាខណ្ឌ ៦។

[46] សារទូរលេខតាមផ្លូវទូតលេខ១៣ កថាខណ្ឌ ៥ និង៦។

[47] សារទូរលេខតាមផ្លូវទូតលេខ១៤ កថាខណ្ឌ ៨។

ការស្នើសុំពិនិត្យភ័ស្តុតាង ស្របតាមវិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង។ ការដាក់បញ្ចូលឯកសារទាំងនេះទៅក្នុងសំណុំរឿង មានសារៈសំខាន់ដល់ការបង្ហាញការពិត ហេតុដូច្នេះ ផលប្រយោជន៍នៃយុត្តិធម៌ តម្រូវឲ្យធ្វើការដាក់បញ្ចូលឯកសារទាំងនេះទុកជាឯកសារភ័ស្តុតាងក្នុងសំណុំរឿង។

៣៥. ហេតុដូច្នេះ មេធាវីការពារក្តីលោក ខៀវ សំផន សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **បង្គាប់**ឲ្យមានការដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សា នូវសារទូរលេខផ្លូវទូតទាំងឡាយដូចមានបញ្ជាក់ក្នុងឧបសម្ពន្ធ ១ និងប្រកាស**ទទួលយក**ឯកសារទាំងនោះទុកជាឯកសារភ័ស្តុតាងក្នុងសំណុំរឿង។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN<br><br>មេធាវី Jacques VERGÈS | ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស<br><br>ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |